Australian Government
Department of Human Services

KHMER

# ពេលវេលាដែលលោកអ្នកនឹងទទួលបានប្រាក់ជំនួយលើកដំបូងរបស់លោកអ្នក

នៅពេលដែលលោកអ្នកដាក់ពាក្យសុំប្រាក់ជំនួយពីយើងខ្ញុំ លោកអ្នកអាចនឹងមិនបានទទួលប្រាក់នោះភ្លាមៗនោះទេ។

ពេលវេលាដែលលោកអ្នកត្រូវរង់ចាំគេហៅថា រយៈពេលរង់ចាំ។ រយៈពេលរង់ចាំនេះមានច្រើនប្រភេទខុសៗគ្នា អាស្រ័យទៅលើស្ថានភាពរបស់លោកអ្នក និងប្រភេទប្រាក់ជំនួយដែលលោកអ្នកដាក់ពាក្យសុំ។

ប្រសិនបើលោកអ្នកបានមកដល់អូស្ត្រាលីដោយសារតែកាន់ទិដ្ឋាការជនភៀសខ្លួនអចិន្ត្រៃយ៍ ឬក៏ទិដ្ឋាការមនុស្សធម៌របស់អូស្ត្រាលី លោកអ្នកមិនចាំបាច់ត្រូវរង់ចាំដើម្បីដាក់ពាក្យសុំប្រាក់ជំនួយនោះឡើយ។ លោកអ្នកអាចដាក់ពាក្យសុំបានភ្លាមៗ។

ប្រាក់ជំនួយរបស់យើងសម្រាប់ជួយដល់ក្រុមគ្រួសារដូចជា Family Tax Benefit (ប្រាក់បំណាច់ពន្ធដារគ្រួសារ), Child Care Subsidy (ប្រាក់បំណាច់ឧបត្ថម្ភលើការមើលថែទាំកុមារ), Additional Child Care Subsidy(ប្រាក់បំណាច់ឧបត្ថម្ភបន្ថែមលើការមើលថែទាំកុមារ), Parental Leave Pay (ប្រាក់បំណាច់សម្រាប់ការឈប់ពីការងារដើម្បីថែកូន), Dad and Partner Pay (ប្រាក់បំណាច់សម្រាប់បិតា និងដៃគូ) និង Double Orphan Pension (ប្រាក់សោធនមើលថែកុមារកំព្រា) គឺមិនមានរយៈពេលនៃការរង់ចាំនោះទេ។ លោកអ្នកអាចដាក់ពាក្យសុំបានភ្លាមៗ។ លោកអ្នកត្រូវតែធ្វើតាមតម្រូវការច្បាប់មួយចំនួនមុននឹងបានប្រាក់ជំនួយ។

## រយៈពេលរង់ចាំប្រសិនបើលោកអ្នកទើបតែមកដល់អូស្ត្រាលីក្នុងពេលថ្មីៗ

ប្រសិនបើលោកអ្នកបានមកដល់អូស្ត្រាលីក្នុងពេលថ្មីៗក្នុងនាមជាពលរដ្ឋអូស្ត្រាលី លោកអ្នកត្រូវរង់ចាំ១០៤សប្តាហ៍ មុននឹងលោកអ្នកអាចទទួលបានប្រាក់ជំនួយរបស់យើងភាគច្រើន និងផលប្រយោជន៍ដទៃទៀត។ ប្រភេទនៃការរង់ចាំនេះហៅថា newly arrived resident′s waiting period (រយៈពេលនៃការរង់ចាំរបស់ពលរដ្ឋថ្មីទើបមកដល់)។

humanservices.gov.au

លោកអ្នកត្រូវតែដាក់ពាក្យសុំទិដ្ឋាការ ហើយបានទទួលទិដ្ឋាការពលរដ្ឋអចិន្ត្រៃយ៍អូស្ត្រាលី។រយៈពេលនៃការរង់ចាំនេះជាទូទៅគឺចាប់ផ្តើមពីថ្ងៃដែលទិដ្ឋាការពលរដ្ឋអចិន្ត្រៃយ៍របស់លោកអ្នកចាប់ផ្តើម គឺមិនមែនរាប់ចាប់ពីថ្ងៃដែលលោកអ្នកបានមកដល់ទឹកដីអូស្ត្រាលីនោះទេ។

ប្រសិនបើលោកអ្នកបានរស់នៅក្នុងប្រទេសមួយដែលមានកិច្ចព្រមព្រៀងសង្គមកិច្ចជាមួយប្រទេសអូស្ត្រាលី លោកអ្នកអាចប្រើកិច្ចព្រមព្រៀងនេះបាន ដើម្បីមានសិទ្ធិទទួលបានប្រាក់ជំនួយ៖

- Age Pension (ប្រាក់សោធនមនុស្សចាស់)
- Disability Support Pension (ប្រាក់ជំនួយជនពិការ) ឬ
- Carer Payment (ប្រាក់ជំនួយអ្នកមើលថែទាំមនុស្ស)

ដើម្បីបានដឹងថាប្រទេសរបស់លោកអ្នកមានកិច្ចព្រមព្រៀងជាមួយនឹងយើងខ្ញុំឬយ៉ាងណា សូមបើកមើលវិបសាយថ៍ **humanservices.gov.au/issa**

### មូលហេតុដែលលោកអ្នកអាចនឹងមិនត្រូវរង់ចាំ

លោកអ្នកអាចបានការលើកលែងពីការរង់ចាំប្រសិនបើលោកអ្នក៖

- ជាពលរដ្ឋសញ្ជាតិអូស្ត្រាលី
- កាន់ប្រភេទទិដ្ឋាការ (subclass) ជាក់លាក់ណាមួយ ឬ
- ជាសមាជិកក្រុមគ្រួសារជនភៀសខ្លួន ឬក៏ជនអន្តោប្រវេសន៍កាន់ទិដ្ឋាការមនុស្សធម៌។

## រយៈពេលរង់ចាំមួយសប្តាហ៍

លោកអ្នកអាចត្រូវរង់ចាំរយៈពេល១សប្តាហ៍មុននឹងមានការចាប់ផ្តើមការបង់ប្រាក់ជំនួយរបស់លោកអ្នក ប្រសិនបើលោកអ្នកដាក់ពាក្យសុំ៖

- Newstart Allowance (ប្រាក់ជំនួយអត់ការងារធ្វើ Newstart)
- Parenting Payment (ប្រាក់ជំនួយសម្រាប់ការចិញ្ចឹមកូន)
- Youth Allowance (ប្រាក់ជំនួយយុវជន) ឬ
- Sickness Allowance (ប្រាក់ឈឺ)។

ការរង់ចាំបែបនេះហៅថា ordinary waiting period (រយៈពេលរង់ចាំធម្មតា)។

### មូលហេតុដែលលោកអ្នកអាចនឹងមិនត្រូវរង់ចាំ

លោកអ្នកអាចបានការលើកលែងពីការរង់ចាំប្រសិនបើលោកអ្នក៖

- ដាក់ពាក្យសុំឡើងវិញក្នុងរយៈពេល១៣អាទិត្យក្រោយពីការបានប្រាក់ជំនួយពីយើងខ្ញុំ ឬក៏ពី Department of Veterans' Affairs Service Pension (ក្រសួងកិច្ចការអតីតយុទ្ធជន) ឬ
- ត្រូវបានគេកំណត់ដឹងថាមានឧបសគ្គធំធេងក្នុងការស្វែងរកការងារធ្វើ។

យើងខ្ញុំអាចនឹងលើកលែងរយៈពេលនៃការរង់ចាំនេះចេញ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងស្ថានភាពហិរញ្ញវត្ថុលំបាកលំបិនខ្លាំង ដោយសារតែវិបត្តិផ្ទាល់ខ្លួនដែលបានកើតឡើងនៅក្នុងរយៈពេល៤សប្តាហ៍កន្លងទៅ។ យើងអាចត្រូវការភស្តុតាងដើម្បីជាការបញ្ជាក់។

## រយៈពេលរង់ចាំប្រសិនបើលោកអ្នកមានប្រាក់សន្សំ ឬប្រាក់ដទៃទៀត

ប្រសិនបើលោកអ្នក ឬដៃគូរបស់លោកអ្នកមានប្រាក់សន្សំ ឬប្រាក់ដទៃទៀតដែលលើសពីកម្រិតជាក់លាក់មួយ លោកអ្នកអាចត្រូវរង់ចាំ មុននឹងបានទទួលប្រាក់ជំនួយ។ ប្រាក់ទាំងនេះរាប់បញ្ចូលទាំងប្រាក់ដែលនិយោជករបស់លោកអ្នកជំពាក់លោកអ្នក។ យើងខ្ញុំនឹងជំរាបលោកអ្នកឲ្យដឹងថាតើលោកអ្នកត្រូវរង់ចាំយូរប៉ុណ្ណានៅពេលដែលលោកអ្នកដាក់ពាក្យ។

រយៈពេលនៃការរង់ចាំនេះហៅថា liquid assets waiting period (រយៈពេលរង់ចាំទ្រព្យសម្បត្តិសាច់ប្រាក់)។ រយៈពេលរង់ចាំនេះអនុវត្តទៅបានប្រសិនបើលោកអ្នកមានថវិកាស្មើនឹង ឬក៏លើសពីចំនួន៖

- $5 500 ប្រសិនបើលោកអ្នកជាបុគ្គលទោលគ្មានកូនក្រោមបន្ទុក ឬ
- $11 000 ប្រសិនបើលោកអ្នកមានដៃគូ ឬប្រសិនបើលោកអ្នកជាបុគ្គលទោលតែមានកូនក្រោមបន្ទុក។

រយៈពេលរង់ចាំនេះអនុវត្តទៅលើប្រភេទប្រាក់ជំនួយដូចខាងក្រោម៖

- Newstart Allowance (ប្រាក់ជំនួយអត់ការងារធ្វើ Newstart)
- Sickness Allowance (ប្រាក់ឈឺ)
- Youth Allowance (ប្រាក់ជំនួយយុវជន) និង
- Austudy (ប្រាក់ជំនួយ Austudy)។

**មូលហេតុដែលលោកអ្នកអាចនឹងមិនត្រូវរង់ចាំ**

លោកអ្នកអាចបានការលើកលែងពីការរង់ចាំប្រសិនបើលោកអ្នក៖

- ឬដៃគូរបស់លោកអ្នកបានរង់ចាំរួចហើយក្នុងរយៈពេលរង់ចាំនេះ នៅក្នុងអំឡុងពេល១២ ខែកន្លងទៅ
- ផ្ទេរពីប្រភេទប្រាក់ជំនួយមួយទៅប្រាក់ជំនួយមួយទៀតក្នុងរយៈពេល១៤ថ្ងៃ
- មានសិទ្ធិអាចទទួលបានប្រាក់ជំនួយ Newstart Allowance ក្រោយពីបានទទួលប្រាក់ជំនួយមួយទៀត
- ស្ថិតក្នុងស្ថានភាពខាងក្រោម៖
  - ក្នុងកម្មវិធីស្ដានីតិសម្បទា
  - កំពុងធ្វើសកម្មភាព Stream C ជាមួយស្ថាប័នរកការងារធ្វើ jobactive ឬ
  - កំពុងធ្វើសកម្មភាពមួយដែលជាផ្នែកនៃ Community Development Programme (កម្មវិធីអភិវឌ្ឍន៍សហាគមន៍)។

យើងខ្ញុំអាចនឹងលើកលែងរយៈពេលនៃការរង់ចាំនេះចេញ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងស្ថានភាពហិរញ្ញវត្ថុលំបាកលំបិនខ្លាំង ដោយសារតែការចំណាយមិនអាចចៀសផុតបាន ឬក៏ការចំណាយសមរម្យផ្សេងៗ។ យើងអាចត្រូវការភស្ដុតាងដើម្បីជាការបញ្ជាក់។

## រយៈពេលរង់ចាំប្រសិនបើលោកអ្នកបានទទួលប្រាក់បំណាច់ដុំនៅពេលលោកអ្នកបានបញ្ចប់ការងារ

ប្រសិនបើនិយោជករបស់លោកអ្នកបានបង់ប្រាក់ដុំដល់លោកអ្នកដូចជាប្រាក់សម្រាប់ពេលឈប់ឈឺ, ប្រាក់សម្រាប់ការលំហែកាយប្រចាំឆ្នាំ ឬប្រាក់បញ្ឈប់ការងារ នៅពេលដែលលោកអ្នកចាកចេញពីការងាររបស់លោកអ្នក លោកអ្នកអាចត្រូវរង់ចាំមួយរយៈពេល មុននឹងអាចទទួលបានប្រាក់ជំនួយពីយើងខ្ញុំ។ រយៈពេលរង់ចាំនេះហៅថា income maintenance period (រយៈពេលរង់ចាំផ្អែកលើប្រាក់ចំណូល)។

រយៈពេលនៃពេលវេលាដែលលោកអ្នកត្រូវរង់ចាំអាស្រ័យទៅលើចំនួនប្រាក់ដែលលោកអ្នក ឬក៏ដៃគូរបស់លោកអ្នកបានទទួលនៅពេលចប់ការងារ។

រយៈពេលនៃការរង់ចាំនេះអនុវត្តទៅលើប្រភេទប្រាក់ជំនួយដូចខាងក្រោម៖

- Austudy (ប្រាក់ជំនួយ Austudy)
- Disability Support Pension (ប្រាក់ជំនួយជនពិការ) លើកលែងតែលោកអ្នកពិការភ្នែកជាអចិន្ត្រៃយ៍
- Newstart Allowance (ប្រាក់ជំនួយអ្នកអត់ការងារធ្វើ Newstart)
- Parenting Payment (ប្រាក់ជំនួយសម្រាប់ការចិញ្ចឹមកូន)
- Sickness Allowance (ប្រាក់ឈឺ)
- Widow Allowance (ប្រាក់ជំនួយមេម៉ាយ)
- Youth Allowance (other) ((ប្រាក់ជំនួយឧបត្ថម្ភយុវជន) (ផ្សេងទៀត))

### មូលហេតុដែលលោកអ្នកអាចនឹងមិនត្រូវរង់ចាំ

យើងខ្ញុំអាចនឹងកាត់បន្ថយ ឬក៏លើកលែងពេលវេលានៃការរង់ចាំ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងស្ថានភាពហិរញ្ញវត្ថុលំបាកលំបិនខ្លាំង។ នេះអាចបណ្តាលមកពីលោកអ្នកបានប្រើប្រាក់បង់ចុងក្រោយពីនិយោជករបស់លោកអ្នកដើម្បីបង់ប្រាក់ចំណាយសមរម្យផ្សេងៗ ឬក៏ចំណាយដែលមិនអាចចៀសផុតបាន។ យើងអាចត្រូវការភស្តុតាងដើម្បីជាការបញ្ជាក់។

## រយៈពេលនៃការរង់ចាំប្រសិនបើលោកអ្នកថ្មីៗនេះទើបបានបញ្ចប់ការងារតាមរដូវ ឬកិច្ចការកុងត្រា

ប្រសិនបើលោកអ្នក ឬដៃគូបានបញ្ចប់កិច្ចការតាមរដូវ, កិច្ចការកុងត្រា ឬកិច្ចការមិនជាប់លាប់ម្តងមានម្តងអត់ នៅក្នុងរយៈពេល៦ខែមុនការដាក់ពាក្យសុំ, លោកអ្នកអាចត្រូវរង់ចាំមុនពេលដែលលោកអ្នកអាចទទួលបានប្រាក់ជំនួយពីយើងខ្ញុំ។ ពេលវេលានៃការរង់ចាំ អាស្រ័យទៅលើចំនួនប្រាក់ដែលលោកអ្នករកបាន និងរយៈពេលដែលលោកអ្នកបានធ្វើការ។

រយៈពេលនេះហៅថា seasonal work preclusion period (រយៈពេលមិនរាប់ការងារតាមរដូវ)។ រយៈពេល seasonal work preclusion period អនុវត្តទៅលើប្រភេទប្រាក់ជំនួយដូចខាងក្រោម៖

- Austudy (ប្រាក់ជំនួយ Austudy)
- Carer Payment (ប្រាក់ជំនួយអ្នកមើលថែទាំមនុស្ស)
- Disability Support Pension (ប្រាក់ជំនួយជនពិការ), លើកលែងតែលោកអ្នកពិការភ្នែកជាអចិន្ត្រៃយ៍
- Newstart Allowance (ប្រាក់ជំនួយអ្នកអត់ការងារធ្វើ Newstart)
- Parenting Payment (ប្រាក់ជំនួយសម្រាប់ការចិញ្ចឹមកូន)

- Partner Allowance (ប្រាក់ជំនួយដៃគូ)
- Sickness Allowance (ប្រាក់ឈឺ)
- Special Benefit (ប្រាក់អត្ថប្រយោជន៍ពិសេស), ប្រសិនបើលោកអ្នកជាអ្នកកាន់ទិដ្ឋាការដែលគេបានស្នើសុំផ្តល់ឲ្យ (nominated visa holder)
- Widow Allowance (ប្រាក់ជំនួយមេម៉ាយ)
- Youth Allowance (ប្រាក់ជំនួយឧបត្ថម្ភយុវជន)។

ឧទាហរណ៍មួយចំនួននៃការងារតាមរដូវ, ការងារកុងត្រា ឬការងារមិនជាប់លាប់ម្តងមានម្តងអត់៖

- ការបេះផ្លែឈើ
- ការប្រមូលផល
- ការកោររោមសត្វ
- ការនេសាទ
- ការងារប្រឹក្សាយោបល់ និង
- ការងារតាមការដ្ឋានសំណង់។

**មូលហេតុដែលលោកអ្នកអាចនឹងមិនត្រូវរង់ចាំ**
លោកអ្នកអាចបានការលើកលែងពីការរង់ចាំប្រសិនបើលោកអ្នក៖

- មានការងារធ្វើរយៈពេលលើសពី១២ខែ
- មានការងារធ្វើ ក្រៅពីការងារតាមរដូវ ដោយបានទទួលនូវការបង់ប្រាក់ឈប់សម្រាកការងារ
- ស្ថិតនៅក្នុងកម្មវិធីស្ពានីតិសម្បទា
- កំពុងធ្វើសកម្មភាព Stream C ជាមួយស្ថាប័នរកការងារធ្វើ jobactive ឬ
- កំពុងធ្វើសកម្មភាពមួយដែលជាផ្នែកនៃ Community Development Programme (កម្មវិធីអភិវឌ្ឍន៍សហគមន៍)។

យើងខ្ញុំអាចលើកលែងពេលវេលានៃការរង់ចាំនេះ ប្រសិនបើលោកអ្នកស្ថិតនៅក្នុងស្ថានភាពហិរញ្ញវត្ថុលំបាកលំបិនខ្លាំង។

## រយៈពេលនៃការរង់ចាំប្រសិនបើលោកអ្នកបានសម្រេចឈប់ធ្វើការរបស់លោកអ្នក ឬក៏បាត់បង់ការងារដោយសារតែប្រព្រឹត្តខុសឆ្គងនៅកន្លែងការងារ

ប្រសិនបើលោកអ្នកបានសម្រេចចិត្តឈប់ធ្វើការងាររបស់លោកអ្នក ឬក៏បានបាត់បង់ការងារ ដោយសារតែការបំពានខុសឆ្គងនៅកន្លែងធ្វើការ លោកអ្នកអាចត្រូវរង់ចាំរយៈពេល៨ ឬ១២សប្តាហ៍មុននឹងលោកអ្នកអាចទទួលបានប្រាក់ជំនួយពីយើងខ្ញុំ។ នេះហៅថា unemployment non-payment period (រយៈពេលរង់ចាំដោយមិនបានប្រាក់អត់ការងារធ្វើ)។

## រយៈពេលរង់ចាំប្រសិនបើលោកអ្នកទើបរើផ្ទះថ្មីៗ ហើយវាធ្វើឲ្យលោកអ្នកបាត់បង់ឱកាសក្នុងការស្វែងរកការងារធ្វើ

ប្រសិនបើលោកអ្នកបានរើផ្ទះនៅក្នុងរយៈពេល៦ខែមុនដឹងដាក់ពាក្យសុំប្រាក់ជំនួយ ហើយវាបានកាត់បន្ថយឱកាសក្នុងការស្វែងរកការងារធ្វើ លោកអ្នកអាចនឹងត្រូវរង់ចាំ២៦សប្តាហ៍។

Moving to an area of lower employment prospects non-payment period (ការរើផ្ទះទៅនៅកន្លែងដែលមិនសម្បូរការងារធ្វើ, រយៈពេលមិនបង់ប្រាក់)នេះអនុវត្តទៅលើ៖

- Newstart Allowance (ប្រាក់ជំនួយអ្នកអត់ការងារធ្វើ Newstart)
- Youth Allowance (other) និង
- Special Benefit (ប្រាក់អត្ថប្រយោជន៍ពិសេស) ក្នុងនាមជាអ្នកកាន់ទិដ្ឋាការដែលគេបានស្នើសុំផ្តល់ឲ្យ

ដើម្បីសម្រេចថាតើលោកអ្នកត្រូវរង់ចាំឬយ៉ាងណា យើងខ្ញុំធ្វើការប្រៀបធៀបកត្តាជាច្រើនរវាងអាសយដ្ឋានចាស់ និងអាសយដ្ឋានថ្មី ដែលក្នុងនោះរួមមាន៖

- ទំហំទីផ្សារការងារ និង
- អត្រាអត់ការងារធ្វើ

## រយៈពេលនៃការរង់ចាំប្រសិនបើលោកអ្នកបានទទួលប្រាក់សងជំងឺចិត្ត

ប្រសិនបើលោកអ្នកបានទទួលប្រាក់ដុំសងជំងឺចិត្ត លោកអ្នកអាចត្រូវរង់ចាំមុននឹងបានទទួលប្រាក់ជំនួយពី Centrelink។ រយៈពេលរង់ចាំនេះហៅថា compensation preclusion period (រយៈពេលមិនរាប់ដោយសារតែបានការសងជំងឺចិត្ត)។

រយៈពេលដែលលោកអ្នកត្រូវរង់ចាំអាស្រ័យទៅលើចំនួនទឹកប្រាក់ដែលលោកអ្នកបានទទួលពីការបង់ប្រាក់សងជំងឺចិត្ត។

## ចំពោះព័ត៌មានបន្ថែម

- សូមចូលទៅវិបសាយថ៍ **humanservices.gov.au** ហើយរាវរកពាក្យ 'waiting periods' សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- សូមចូលទៅវិបសាយថ៍ **humanservices.gov.au/yourlanguage** ជាទីដែលលោកអ្នកអាចអាន, ស្តាប់ ឬក៏មើលវីដេអូដែលមានព័ត៌មានជាភាសារបស់លោកអ្នក
- ទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងខ្ញុំជាភាសារបស់លោកអ្នកអំពីប្រាក់ជំនួយ និងសេវាកម្មនានារបស់ Centrelink
- ទូរសព្ទទៅសេវាកម្មបកប្រែភាសា Translating and Interpreting Service (TIS National) តាមលេខ **131 450** ដើម្បីនិយាយជាមួយយើងខ្ញុំជាភាសារបស់លោកអ្នកអំពីកិច្ចការ Medicare និង Child Support (សេវាកម្មឧបត្ថម្ភគាំទ្រកុមារ) ហើយនិងប្រាក់ជំនួយ
- អញ្ជើញទៅមជ្ឈមណ្ឌលសេវាកម្មដោយផ្ទាល់។

កំណត់សម្គាល់៖ ការហៅចេញពីលេខទូរសព្ទតាមផ្ទះរបស់លោកអ្នកទៅកាន់លេខទូរសព្ទដែលចាប់ផ្តើមដោយលេខ '13' ពីគ្រប់ទីកន្លែងនៅក្នុងប្រទេសអូស្ត្រាលី គឺត្រូវអស់ប្រាក់ក្នុងអត្រាតម្លៃមួយថេរ។ អត្រាថេរនោះអាចខុសគ្នាពីតម្លៃនៃទូរសព្ទក្នុងតំបន់ ហើយក៏អាចខុសគ្នារវាងក្រុមហ៊ុនផ្តល់សេវាកម្មទូរសព្ទផងដែរ។ ការហៅទៅលេខ '1800' ចេញពីលេខទូរសព្ទតាមផ្ទះរបស់លោកអ្នក គឺមិនគិតថ្លៃទេ។ ការហៅទូរសព្ទពីលេខទូរសព្ទសាធារណៈ និងពីទូរសព្ទដៃអាចត្រូវគេគិតថ្លៃទៅតាមរយៈពេលនៃការនិយាយ៕

## សេចក្តីប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះគឺក្នុងគោលបំណងគ្រាន់តែជាការណែនាំផ្តល់ព័ត៌មានអំពីប្រាក់ជំនួយ និងសេវាកម្មប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់លោកអ្នកក្នុងការសម្រេចចិត្តដាក់ពាក្យសុំប្រាក់ជំនួយ ហើយនិងការដាក់ពាក្យទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់លោកអ្នក។

Australian Government
Department of Human Services

ENGLISH

# When you will get your first payment

When you claim a payment from us, you may not get paid straight away.

The time you have to wait is called a waiting period. There are different types of waiting periods depending on your situation and which payment you are claiming.

If you arrived in Australia on an Australian permanent refugee or humanitarian visa, you do not have to wait to claim payments. You can claim immediately.

Our family payments, such as Family Tax Benefit, Child Care Subsidy, Additional Child Care Subsidy, Parental Leave Pay, Dad and Partner Pay and Double Orphan Pension do not have waiting periods. You can claim straight away. You need to meet certain rules to be paid.

## Waiting period if you recently arrived in Australia

If you recently arrived in Australia as an Australian resident, you have to wait 104 weeks before you can get most of our payments and other benefits. This is called the newly arrived resident's waiting period.

You must apply for and be granted an Australian permanent resident visa. The waiting period generally starts from the date your permanent resident visa starts, not from when you arrived in Australia.

If you have lived in a country that has a social security agreement with Australia, you may use this agreement to be eligible for:

- Age Pension
- Disability Support Pension, or
- Carer Payment

To find out if your country has an agreement with us go to **humanservices.gov.au/issa**

### Why you may not have to wait

You may be exempt from waiting if you:

- are an Australian citizen
- hold a certain visa subclass, or
- are the family member of a refugee or humanitarian migrant.

## One week waiting period

You may need to wait one week for your payments to start if you are claiming:

- Newstart Allowance
- Parenting Payment
- Youth Allowance, or
- Sickness Allowance.

This is called an ordinary waiting period.

**Why you may not have to wait**
You may be exempt from waiting if you:

- reclaim within 13 weeks of getting a payment from us or a Department of Veterans' Affairs Service Pension, or
- have been identified as having significant barriers to finding work

We may waive this waiting period if you are in severe financial hardship because of a personal crisis that happened in the past four weeks. We may need evidence.

## Waiting period if you have savings or other money

If you or your partner have savings or other money over a certain limit, you may have to wait to get your payment. This includes money your employer owes you. We will let you know how long you have to wait when you submit your claim.

This is called the liquid assets waiting period. It applies if you have funds equal to or more than:

- $5 500 if you are single with no dependants, or
- $11 000 if you have a partner, or you are single with dependent children.

This applies for the following payments:

- Newstart Allowance
- Sickness Allowance
- Youth Allowance, and
- Austudy.

**Why you may not have to wait**
You may be exempt from waiting if you:

- or your partner have served this waiting period in the last 12 months
- transfer from one payment to another within 14 days
- qualified for Newstart Allowance after getting another payment
- are:
  - in a rehabilitation program
  - doing a Stream C activity with your jobactive provider, or
  - doing an activity as part of the Community Development Programme.

We may waive this waiting period if you are in severe financial hardship because of unavoidable or reasonable expenses. We may need evidence.

## Waiting period if you got a lump sum payment when you finished work

If your employer paid you a lump sum such as sick leave, annual leave or a redundancy, when you left your job, you may have to wait before you can get a payment from us. This is called an income maintenance period.

The length of time you have to wait depends on the amount you or your partner got paid when you finished work.

This applies for the following payments:

- Austudy
- Disability Support Pension, except if you are permanently blind
- Newstart Allowance
- Parenting Payment
- Sickness Allowance
- Widow Allowance
- Youth Allowance (other)

**Why you may not have to wait**
We may reduce or waive the waiting time if you are in severe financial hardship. This could be because you have used your final payment from your employer to pay unavoidable or reasonable expenses. We may need evidence.

## Waiting period if you recently finished seasonal or contract work

If you or your partner finished seasonal, contract or intermittent work in the six months before claiming, you may have to wait before you can get a payment from us. The length of time you have to wait depends on how much you earned and how long you were working.

This is called the seasonal work preclusion period. It applies for the following payments:

- Austudy
- Carer Payment
- Disability Support Pension, except if you are permanently blind
- Newstart Allowance
- Parenting Payment
- Partner Allowance
- Sickness Allowance
- Special Benefit, if you are a nominated visa holder
- Widow Allowance
- Youth Allowance.

Examples of seasonal, contract and intermittent work:

- fruit picking
- harvesting
- shearing
- fishing
- consultancy work, and
- work on building sites.

**Why you may not have to wait**
You may be exempt from waiting if you:

- have a job that will last more than 12 months
- have a job, other than seasonal work, where they paid you leave entitlements

- are in a rehabilitation program
- are doing a Stream C activity with your jobactive provider, or
- are doing an activity as part of the Community Development Programme.

We may waive this waiting period if you are in severe financial hardship.

### Waiting period if you chose to leave your job or lost it due to misconduct

If you chose to leave your job or lost it due to misconduct, you may need to wait eight or 12 weeks before you can get a payment from us. This is called an unemployment non-payment period.

### Waiting period if you recently moved and it reduced your chances of finding work

If you moved in the six months before claiming and it reduced your chances of getting a job you may have to wait 26 weeks.

The moving to an area of lower employment prospects non-payment period applies to:

- Newstart Allowance
- Youth Allowance (other), and
- Special Benefit as a nominated visa holder

To decide if you have to wait, we compare factors at your old and new addresses, including:

- size of labour markets, and
- unemployment rates

### Waiting period if you have had a compensation payment

If you have had a lump sum compensation payment you may have to wait to get a Centrelink payment. This is called a compensation preclusion period. It applies for most of our payments.

How long you have to wait will depend on how much your compensation payment was.

## For more information

- go to **humanservices.gov.au** and search for ‘waiting periods’ for more information in English
- go to **humanservices.gov.au/yourlanguage** where you can read, listen to or watch videos with information in your languages
- call **131 202** to speak with us in your language about Centrelink payments and services
- call the Translating and Interpreting Service (TIS National) on **131 450** to speak with us in your language about Medicare and Child Support payments and services
- visit a service centre.

Note: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It is your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.